ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ


សាកលវិទ្យាល័យ កម្ពុជា
University of Cambodia


លេខ៖...០២៤០៥០៣......ស.កឍ


**Colleges**
Arts & Humanities
Education
Law
Management
Science & Technology
Social Sciences

**Institutes**
Institute of Research & Advanced Studies
Institute of Technical & Professional Training

**Centers**
Center for ASEAN & East Asian Studies
Center for English Studies
Center for International Studies

**Asia**
Leadership Center


# ការចុះឈ្មោះសិក្សា សំរាប់វគ្គសិក្សាទី៣
# ឆ្នាំសិក្សា ២០១៣_២០១៤

សាកលវិទ្យាល័យកម្ពុជាសូមជំរាបដល់ និស្សិតទាំងអស់ដែលមានបំណង ចង់ចុះឈ្មោះសិក្សា ក្នុង វគ្គសិក្សាទី3 (ថ្ងៃទី១៤ ខែកក្កដា ដល់ ថ្ងៃទី០៥ ខែតុលា ឆ្នាំ ២០១៤) ឆ្នាំសិក្សា២០១៣-២០១៤ សម្រាប់គ្រប់កម្មវិធីសិក្សា (ថ្នាក់បរិញ្ញាបត្រ, បរិញ្ញាបត្រ ជាន់ខ្ពស់, និងថ្នាក់បណ្ឌិត) ថា៖

<u>ការចុះឈ្មោះសំរាប់និស្សិតទាំងអស់ចាប់ផ្តើមពីថ្ងៃទី **០២ ខែមិថុនា ឆ្នាំ ២០១៤**</u>

➢ *សូមកំណត់ចំណាំ នូវថ្ងៃផុតកំណត់ដូចខាងក្រោម៖*

| ស្ថានភាព | | ថ្ងៃផុតកំណត់សំរាប់ | |
|---|---|---|---|
| | | ការចុះឈ្មោះ<br>*(សូមមើលចំណាំ ១)* | ការបង់ថ្លៃ<br>*(សូមមើលចំណាំ ២)* |
| **និស្សិតចាស់** | - និស្សិតអាហារូបករណ៍<br>- និស្សិតបង់ថ្លៃពេញ | ០៤ ខែកក្កដា ឆ្នាំ ២០១៤ | ១០ ខែកក្កដា ឆ្នាំ២០១៤ |
| | និស្សិតផ្ទេរការសិក្សា | ២១ ខែកក្កដា ឆ្នាំ២០១៤ | ២១ ខែកក្កដា ឆ្នាំ២០១៤ |
| ការប្តូរជំនាញ និង/ឬវេនសិក្សា | | ០១ ខែកក្កដា ឆ្នាំ២០១៤ | ០៧ខែកក្កដា ឆ្នាំ២០១៤ |

<u>ចំណាំ ១</u>: និស្សិតទាំងអស់ <u>រួមទាំងនិស្សិតអាហារូបករណ៍ផង</u> នឹងត្រូវបង់ប្រាក់បន្ថែម ២០ដុល្លារអាមេរិក ប្រសិនបើចុះឈ្មោះក្រោយកាលបរិច្ឆេទ។

<u>ចំណាំ ២</u>: និស្សិតទាំងអស់<u>រួមទាំងនិស្សិតអាហារូបករណ៍ផង</u> នឹងត្រូវបង់ប្រាក់បន្ថែម ៥% (នៃតម្លៃពេញធម្មតា) ជាការពិន័យ ចំពោះ ការបង់ប្រាក់យឺតសំរាប់សប្តាហ៍នីមួយៗ ដើម្បីឲ្យគេបានចូលរៀន។

ប្រសិនបើ មិនបានបង់ប្រាក់ ក្នុងរយៈពេលបួនសប្តាហ៍ដំបូង(២០%នៃតំលៃដែលបង់យឺត) និស្សិតនឹងត្រូវ ចាត់ទុកថាបានបោះបង់ការសិក្សាចោល ហើយពិន្ទុនៃការដកឈ្មោះ( WD ) នេះនឹងត្រូវបានកត់ត្រាទុក នៅលើព្រឹត្តិប័ត្រពិន្ទុរបស់គេ។


***UC Main Campus:*** Sleng Roleung Village, Northbridge Road, Sangkat Toek Thla, Khan Sen Sok, Phnom Penh, Cambodia. ***Mailing Address:*** P.O.Box 917, Phnom Penh 12000, Cambodia; Central Office Phone: (855-23) 993274, Fax: (855-23) 993284, Information: (855-23)993276; ***Email:***info@uc.edu.kh, admissions@uc.edu.kh, library@uc.edu.kh, ***Website:***www.uc.edu.kh

សូមចំណាំផងដែរថា មុខវិជ្ជាដែលបានចុះរួចហើយ អាចត្រូវបាន**<u>បន្ថែម ឬ ដកចេញ</u>** ក្នុងរយៈពេល<u>មួយសប្តាហ៍មុនពេលចាប់ផ្តើម នៃវគ្គសិក្សា **(០៧ ខែកក្កដា ឆ្នាំ ២០១៤ )**</u> ដោយមានការយល់ព្រមពីព្រឹទ្ធបុរសរងជាមុន។ពេលដែលនិស្សិតសម្រេចចិត្តដកមុខវិជ្ជាណាមួយ ដោយហេតុផលអ្វីក៏ដោយ បន្ទាប់ពី ថ្ងៃផុត កំណត់នេះ៖

I. មុខវិជ្ជានេះនឹងចេញ <u>(WD)លើព្រឹត្តិប័ត្រពិន្ទុរបស់និស្សិត</u> បើសិននិស្សិតបានជូនដំណឹងដល់ ព្រឹទ្ធបុរសរងយ៉ាងយូរត្រឹមថ្ងៃចុងក្រោយនៃសប្តាហ៍ដំបូងនៃវគ្គសិក្សាវានឹងមិនប៉ះពាល់ដល់ GPA របស់គេទេ។

II. បន្ទាប់ពីនោះ មុខវិជ្ជានេះនឹងចេញ <u>(F) (Grade Point= 0) នៅលើព្រឹត្តិប័ត្រពិន្ទុរបស់គេ</u> លើកលែងតែក្នុងកាលៈទេសៈ ហួសពីការគ្រប់គ្រងរបស់និស្សិត (ដែលWD នឹងត្រូវបានកត់ត្រាទុកជំនួសវិញ បើមានឯកសារជាភស្តុតាងភ្ជាប់មកទាន់ពេលវេលា)។

III. ចំណាំថា ប្រសិនបើនិស្សិតមានបំណងឈប់សម្រាក រយៈពេលយូរនោះ ពិន្ទុបែបនេះ(WD) ឬ (F) នឹងមិនត្រូវបានយកមកអនុវត្តឡើយ។

**ការប្តូរវេនសិក្សា ឬ ការប្តូរជំនាញ** ជាដំបូង និស្សិតត្រូវទៅជួបជាមួយ ព្រឹទ្ធបុរសរង ដើម្បីជំរាបពីគោលបំណងរបស់ខ្លួននិងទទួលបានការអនុញ្ញាតជាមុនសិនដើម្បីទទួលបានលិខិតដែលពាក់ព័ន្ធ

I. និស្សិតអាចប្តូរជំនាញបានក្នុងអំឡុងពេលនៃការចុះឈ្មោះ មុនពេលចាប់ផ្តើមនៃវគ្គសិក្សា បន្ទាប់ពីគេបានបញ្ចប់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន។

II. និស្សិតធម្មតាអាចប្តូរវេន ឬ ជំនាញដោយមិនមានការបង់ថ្លៃទេ ប៉ុន្តែនិស្សិតអាហារូបករណ៍ (ពេញ និងមិនពេញ) ត្រូវបង់តំលៃសមរម្យ នៅពេលដែលការប្តូរនេះត្រូវបានអនុញ្ញាត។

វាជាការសំខាន់ណាស់ ដែលនិស្សិតត្រូវចុះឈ្មោះអោយបានលឿន ដូច្នេះទើបអាចដឹងថា ថ្នាក់ណានឹង ត្រូវបើក ហើយថ្នាក់ណានឹងត្រូវបិទដោយសារការចុះឈ្មោះមិនគ្រប់គ្រាន់។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង ការិយាល័យសិក្សានិងសេវានិស្សិត ឬការិយាល័យផ្តល់ពត៌មានទទួលពត៌មាន និង ចុះឈ្មោះ ឬ តាមទូរស័ព្ទ : **០២៣ ៩៩៣ ២៧៤ , ០២៣ ៩៩៣ ២៧៦** ។

ភ្នំពេញ ថ្ងៃទី១៧ ខែ ឧសភា ឆ្នាំ២០១៤

**ជ.សាកលវិទ្យាធិការ**

**សាកលវិទ្យាធិការរង**

**បណ្ឌិត អ៊ុី រតនា**

ចម្លងជូនៈ - *សាកលវិទ្យាធិការ*

- *សាកលវិទ្យាធិការរង*
- *ព្រឹទ្ធបុរសនិង ព្រឹទ្ធបុរសរង*
- *ការិយាល័យសិក្សានិងសេវានិស្សិត*
- *ការិយាល័យដែលពាក់ព័ន្ធ*